**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៤១ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការកែសម្រួលមាត្រា៤នៃអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០១/៤៥០ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០០១ ស្តីពីបៀវត្សមូលដ្ឋាននិងប្រាក់បន្ទាប់បន្សំនៃបៀវត្សរបស់មន្ត្រីរាជការស៊ីវិល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី០២ ខែតុលា ឆ្នាំ២០១៤ ស្តីពីគោលការណ៍រួមនៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់របាសម្ព័ន្ធគ្រប់គ្រង និង មុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**សម្រេច**

**មាត្រាមួយ .-**

ត្រូវបានធ្វើការកែសម្រួលមាត្រា៤នៃអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល ដូចតទៅ៖



www.pheakdeylaw.com

**មាត្រា៤ .. ថ្មី**

ប្រាក់បំណាច់មុខងារ គឺជាប្រាក់បន្ថែមលើបៀវត្សមូលដ្ឋានប្រចាំខែរបស់មន្ត្រីរាជការស៊ីវិលដែលកំពុងបំពេញមុខងារក្នុងមុខតំណែងតាមរចនាសម្ព័ន្ធរបស់ក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

ប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល ត្រូវបានរៀបចំនិងកែសម្រួល ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រាពីរ ..**

ប្រាក់បំណាច់មុខងារដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ត្រូវផ្តល់ជូនមន្ត្រីរាជការស៊ីវិលចាប់ពីថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦តទៅ។

**មាត្រាបី ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ២០១៦

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រាបី
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com

ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួលមាត្រា៤នៃអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៥ ស្ដីពីការកែសម្រួលប្រាក់បំណាច់មុខងារមន្ត្រីរាជការស៊ីវិល។

១. វិស័យរដ្ឋបាល ការទូត និងបច្ចេកទេស

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១ | អគ្គលេខាធិការរាជរដ្ឋាភិបាល | ១ ៧៥០ ០០០ |
| ២ | អគ្គលេខាធិការរងរាជរដ្ឋាភិបាល | ១ ៤០០ ០០០ |
| ៣ | អគ្គលេខាធិការនៃក្រសួង ស្ថាប័ន | ១ ០០០ ០០០ |
| ៤ | អគ្គនាយក | ៩៣០ ០០០ |
| ៥ | អគ្គាធិការ | ៩២០ ០០០ |
| ៦ | អភិបាលរាជធានី ខេត្ត | ៩១០ ០០០ |
| ៧ | អគ្គលេខាធិការរងនៃក្រសួង ស្ថាប័ន | ៨៨០ ០០០ |
| ៨ | អគ្គនាយករង | ៨៥០ ០០០ |
| ៩ | អគ្គាធិការរង | ៨៣០ ០០០ |
| ១០ | អភិបាលរងរាជធានី ខេត្ត | ៨២០ ០០០ |
| ១១ | ប្រធាននាយកដ្ឋាន | ៨២០ ០០០ |
| ១២ | អធិការថ្នាក់កណ្ដាល | ៧៩០ ០០០ |
| ១៣ | នាយករដ្ឋបាលសាលារាជធានី ខេត្ត | ៧៩០ ០០០ |
| ១៤ | អនុប្រធាននាយកដ្ឋាន | ៧១០ ០០០ |
| ១៥ | ប្រធានអង្គភាពលទ្ធកម្ម(ថ្នាក់កណ្ដាល) | ៧១០ ០០០ |
| ១៦ | អភិបាលក្រុង ស្រុក ខណ្ឌ | ៧០០ ០០០ |
| ១៧ | អធិការរដ្ឋបាលព្រៃឈើ | ៧០០ ០០០ |
| ១៨ | អធិការរដ្ឋបាលជលផល | ៧០០ ០០០ |
| ១៩ | នាយករងរដ្ឋបាលសាលារាជធានី ខេត្ត | ៧០០ ០០០ |
| ២០ | ប្រធានមន្ទីរជំនាញរាជធានី ខេត្ត | ៧០០ ០០០ |
| ២១ | អធិការរងថ្នាក់កណ្ដាល | ៧០០ ០០០ |
| ២២ | ក្រឡាបញ្ជី | ៦៨០ ០០០ |
| ២៣ | ប្រធានការិយាល័យថ្នាក់កណ្ដាល | ៤៩០ ០០០ |
| ២៤ | អនុប្រធានអង្គភាពលទ្ធកម្ម(ថ្នាក់កណ្ដាល) | ៤៩០ ០០០ |
| ២៥ | អភិបាលរងក្រុង ស្រុក ខណ្ឌ | ៤២០ ០០០ |
| ២៦ | នាយកទីចាត់ការសាលារាជធានី ខេត្ត | ៤២០ ០០០ |
| ២៧ | អនុប្រធានមន្ទីរជំនាញរាជធានី ខេត្ត | ៤២០ ០០០ |
| ២៨ | ប្រធានអង្គភាពលទ្ធកម្មរាជធានី ខេត្ត | ៤២០ ០០០ |
| ២៩ | នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ | ៤២០ ០០០ |
| ៣០ | អនុប្រធានការិយាល័យថ្នាក់កណ្ដាល | ៣២០ ០០០ |
| ៣១ | នាយករងទីចាត់ការសាលារាជធានី ខេត្ត | ៣២០ ០០០ |
| ៣២ | អនុប្រធានអង្គភាពលទ្ធកម្មរាជធានី ខេត្ត | ៣២០ ០០០ |
| ៣៣ | នាយករងរដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ | ៣២០ ០០០ |



www.pheakdeylaw.com

| | | |
|---|---|---|
| ៣៤ | ប្រធានការិយាល័យសាលារាជធានី ខេត្ត | ៣២០ ០០០ |
| ៣៥ | ប្រធានការិយាល័យមន្ទីរជំនាញរាជធានី ខេត្ត | ៣២០ ០០០ |
| ៣៦ | អនុប្រធានការិយាល័យសាលារាជធានី ខេត្ត | ៣១០ ០០០ |
| ៣៧ | ប្រធានការិយាល័យសាលាក្រុង ស្រុក ខណ្ឌ | ៣០០ ០០០ |
| ៣៨ | ប្រធានអង្គភាពលទ្ធកម្ម ក្រុង ស្រុក ខណ្ឌ | ៣០០ ០០០ |
| ៣៩ | អនុប្រធានការិយាល័យមន្ទីរជំនាញរាជធានី ខេត្ត | ៣០០ ០០០ |
| ៤០ | ប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ | ៣០០ ០០០ |
| ៤១ | អនុប្រធានអង្គភាពលទ្ធកម្ម ក្រុង ស្រុក ខណ្ឌ | ២៨០ ០០០ |
| ៤២ | អនុប្រធានការិយាល័យជំនាញក្រុង ស្រុក ខណ្ឌ | ២៨០ ០០០ |
| ៤៣ | អនុប្រធានការិយាល័យសាលាក្រុង ស្រុក ខណ្ឌ | ២៨០ ០០០ |
| ៤៤ | មន្ត្រីគ្រប់គ្រងរដ្ឋបាល ឬមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ឬមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ឬមន្ត្រីការទូតជាន់ខ្ពស់ | ២៧០ ០០០ |
| ៤៥ | ស្មៀនឃុំ សង្កាត់ | ២៦០ ០០០ |
| ៤៦ | មន្ត្រីក្រមការ ឬមន្ត្រីបច្ចេកទេសមធ្យម ឬមន្ត្រីក្រមការកិច្ចការបរទេស | ២៦០ ០០០ |
| ៤៧ | លេខាធិការរដ្ឋបាល ឬមន្ត្រីបច្ចេកទេសបឋម | ២៥០ ០០០ |

២. វិស័យអប់រំ

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១ | សកលវិទ្យាធិការ | ៨៨០ ០០០ |
| ២ | នាយកវិទ្យាស្ថានជាតិអប់រំ | ៨៨០ ០០០ |
| ៣ | នាយកវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ៨៨០ ០០០ |
| ៤ | សកលវិទ្យាធិការរង | ៨២០ ០០០ |
| ៥ | នាយករងវិទ្យាស្ថានជាតិអប់រំ | ៨២០ ០០០ |
| ៦ | នាយករងវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា | ៨២០ ០០០ |
| ៧ | ព្រឹទ្ធបុរសមហាវិទ្យាល័យ | ៧៩០ ០០០ |
| ៨ | ប្រធានមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | ៧៩០ ០០០ |
| ៩ | នាយកវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា | ៧៩០ ០០០ |
| ១០ | សាស្ត្រាចារ្យ | ៧៩០ ០០០ |
| ១១ | ព្រឹទ្ធបុរសរងមហាវិទ្យាល័យ | ៧៨០ ០០០ |
| ១២ | សាស្ត្រាចារ្យរង | ៧៥០ ០០០ |
| ១៣ | អនុប្រធានមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា | ៧០០ ០០០ |
| ១៤ | នាយករងវិទ្យាស្ថានជាតិអប់រំកាយ និងកីឡា | ៧០០ ០០០ |
| ១៥ | សាស្ត្រាចារ្យជំនួយ | ៧០០ ០០០ |
| ១៦ | អធិការមធ្យមសិក្សា | ៥០០ ០០០ |
| ១៧ | នាយកមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ៥០០ ០០០ |
| ១៨ | គ្រូឧទ្ទេសឧត្តមសិក្សា(ក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម) | ៥០០ ០០០ |
| ១៩ | ប្រធានដេប៉ាតឺម៉ង់ | ៤៨០ ០០០ |
| ២០ | នាយកសាលាមធ្យមសិក្សាគរុកោសល្យមត្តេយ្យមជ្ឈិម | ៤៨០ ០០០ |
| ២១ | នាយកសាលាគរុកោសល្យនិងក្រឹតការរាជធានីខេត្ត | ៤៨០ ០០០ |
| ២២ | អនុប្រធានដេប៉ាតឺម៉ង់ | ៤៧០ ០០០ |



www.pheakdeylaw.com

| | | |
|---|---|---|
| ២៣ | គ្រូបង្រៀនកម្រិតឧត្តម (បង្រៀននៅឧត្តមសិក្សា) | ៤៧០ ០០០ |
| ២៤ | នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូអប់រំកាយនិងកីឡា | ៤៥០ ០០០ |
| ២៥ | នាយករងមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ | ៤២០ ០០០ |
| ២៦ | នាយកវិទ្យាល័យ | ៤១០ ០០០ |
| ២៧ | នាយកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤១០ ០០០ |
| ២៨ | នាយកសាលាបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤១០ ០០០ |
| ២៩ | នាយកការដ្ឋានសាលាបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៤១០ ០០០ |
| ៣០ | នាយករងមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូអប់រំកាយនិងកីឡា | ៤០០ ០០០ |
| ៣១ | នាយករងសាលាមធ្យមសិក្សាគរុកោសល្យមធ្យមដ្ឋាន | ៤០០ ០០០ |
| ៣២ | នាយករងសាលាគរុកោសល្យនិងក្រឹតការាជធានីខេត្ត | ៤០០ ០០០ |
| ៣៣ | អធិការបឋមសិក្សា | ៤០០ ០០០ |
| ៣៤ | នាយករងវិទ្យាល័យ | ៣៩០ ០០០ |
| ៣៥ | នាយករងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៣៩០ ០០០ |
| ៣៦ | នាយករងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៣៩០ ០០០ |
| ៣៧ | នាយករងការដ្ឋានសាលាបណ្តុះបណ្តាលវិជ្ជាជីវៈនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ៣៩០ ០០០ |
| ៣៨ | នាយកអនុវិទ្យាល័យ | ៣៩០ ០០០ |
| ៣៩ | គ្រូឧទ្ទេសមធ្យមសិក្សាទុតិយភូមិ(ក្របខណ្ឌគ្រូបង្រៀនកម្រិតឧត្តម) | ៣៩០ ០០០ |
| ៤០ | គ្រូបង្រៀនកម្រិតឧត្តម(បង្រៀននៅវិទ្យាល័យ) | ៣៨០ ០០០ |
| ៤១ | គ្រូបង្រៀនកម្រិតឧត្តម(បង្រៀននៅមជ្ឈមណ្ឌល សាលា និងការដ្ឋានសាលានៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ) | ៣៨០ ០០០ |
| ៤២ | នាយករងអនុវិទ្យាល័យ | ៣៨០ ០០០ |
| ៤៣ | នាយកសាលាមត្តេយ្យសិក្សា | ៣៨០ ០០០ |
| ៤៤ | នាយកសាលាបឋមសិក្សា | ៣៨០ ០០០ |
| ៤៥ | គ្រូឧទ្ទេសកម្រិតមូលដ្ឋាន(ក្របខណ្ឌគ្រូបង្រៀនកម្រិត មូលដ្ឋាន) | ៣៨០ ០០០ |
| ៤៦ | នាយករងមត្តេយ្យសិក្សា | ៣៧០ ០០០ |
| ៤៧ | នាយករងសាលាបឋមសិក្សា | ៣៧០ ០០០ |
| ៤៨ | គ្រូបង្រៀនកម្រិតមូលដ្ឋាន | ៣៧០ ០០០ |
| ៤៩ | គ្រូបង្រៀនកម្រិតមូលដ្ឋាន(បង្រៀននៅមជ្ឈមណ្ឌល សាលា និងការដ្ឋានសាលានៃក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ) | ៣៧០ ០០០ |
| ៥០ | គ្រូឧទ្ទេសបឋម(ក្របខណ្ឌគ្រូបង្រៀនកម្រិតបឋម) | ៣៧០ ០០០ |
| ៥១ | គ្រូបង្រៀនកម្រិតបឋម | ៣៥០ ០០០ |



www.pheakdeylaw.com

៣. វិស័យសុខាភិបាល

| ល.រ | បរិយាយ | ប្រាក់បំណាច់មុខងារ(រៀល) |
|---|---|---|
| ១ | នាយកវិទ្យាស្ថានជាតិនៃក្រសួងសុខាភិបាល | ៧៩០ ០០០ |
| ២ | ប្រធានឃ្លាំងឱសថកណ្តាល | ៧៩០ ០០០ |
| ៣ | នាយកមន្ទីរពេទ្យជាតិ | ៧៩០ ០០០ |
| ៤ | នាយកសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ | ៧៩០ ០០០ |
| ៥ | ប្រធានមជ្ឈមណ្ឌលជាតិនៃក្រសួងសុខាភិបាល | ៧៩០ ០០០ |
| ៦ | សាស្ត្រាចារ្យមហាបរិញ្ញា | ៧៩០ ០០០ |
| ៧ | នាយករងសាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ | ៧០០ ០០០ |
| ៨ | នាយករងវិទ្យាស្ថានជាតិនៃក្រសួងសុខាភិបាល | ៧០០ ០០០ |
| ៩ | នាយករងមន្ទីរពេទ្យជាតិ | ៧០០ ០០០ |
| ១០ | អនុប្រធានមជ្ឈមណ្ឌលជាតិ | ៧០០ ០០០ |
| ១១ | អនុប្រធានឃ្លាំងឱសថកណ្តាល | ៧០០ ០០០ |
| ១២ | នាយកសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ | ៧០០ ០០០ |
| ១៣ | ប្រធានមន្ទីរពេទ្យបង្អែករាជធានី ខេត្ត | ៦០០ ០០០ |
| ១៤ | វេជ្ជបណ្ឌិតឯកទេស | ៥៥០ ០០០ |
| ១៥ | បណ្ឌិតឱសថសាស្ត្រឯកទេស/ឱសថបណ្ឌិត | ៥៥០ ០០០ |
| ១៦ | បណ្ឌិតសុខភាពសាធារណៈ | ៥៥០ ០០០ |
| ១៧ | បណ្ឌិតវិទ្យាសាស្ត្រសុខាភិបាល | ៥៥០ ០០០ |
| ១៨ | វេជ្ជបណ្ឌិត(ជំនាញ/អនុបណ្ឌិត) | ៥៣០ ០០០ |
| ១៩ | ទន្តបណ្ឌិត(ជំនាញ/អនុបណ្ឌិត/ឯកទេស) | ៥២០ ០០០ |
| ២០ | វេជ្ជបណ្ឌិត | ៤៦០ ០០០ |
| ២១ | ឱសថការី | ៤៥០ ០០០ |
| ២២ | ទន្តបណ្ឌិត | ៤៥០ ០០០ |
| ២៣ | មន្ត្រីសុខភាពសាធារណៈ(បរិញ្ញាបត្រជាន់ខ្ពស់សុខភាពសាធារណៈ) | ៤៥០ ០០០ |
| ២៤ | ប្រធានការិយាល័យស្រុកប្រតិបត្តិ | ៤២០ ០០០ |
| ២៥ | ប្រធានមន្ទីរពេទ្យបង្អែកស្រុក | ៤២០ ០០០ |
| ២៦ | អនុប្រធានមន្ទីរពេទ្យបង្អែករាជធានី ខេត្ត | ៤២០ ០០០ |
| ២៧ | នាយករងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគ | ៤២០ ០០០ |
| ២៨ | អនុប្រធានការិយាល័យស្រុកប្រតិបត្តិ | ៤១០ ០០០ |
| ២៩ | ឱសថការីមធ្យម | ៤១០ ០០០ |
| ៣០ | គ្រូពេទ្យមធ្យម | ៤១០ ០០០ |
| ៣១ | ទន្តពេទ្យមធ្យម | ៤១០ ០០០ |
| ៣២ | អនុប្រធានមន្ទីរពេទ្យបង្អែកក្រុង ស្រុក ខណ្ឌ | ៣៩០ ០០០ |
| ៣៣ | ប្រធានមណ្ឌលសុខភាព | ៣៩០ ០០០ |
| ៣៤ | អនុប្រធានមណ្ឌលសុខភាព | ៣៨០ ០០០ |
| ៣៥ | គិលានុបដ្ឋាកឯកទេស | ៣៨០ ០០០ |
| ៣៦ | គិលានុបដ្ឋាក(បរិញ្ញាបត្រ) | ៣៨០ ០០០ |



www.pheakdeylaw.com

| | | |
|---|---|---|
| ៣៧ | ឆ្មប(បរិញ្ញាបត្រ) | ៣៨០ ០០០ |
| ៣៨ | មន្ត្រីសុខភាពសាធារណៈ(បរិញ្ញាបត្រសុខភាពសាធារណៈ) | ៣៨០ ០០០ |
| ៣៩ | អ្នកព្យាបាលដោយចលនាមធ្យម | ៣៧០ ០០០ |
| ៤០ | អ្នកបច្ចេកទេសមន្ទីរពិសោធន៍មធ្យម | ៣៧០ ០០០ |
| ៤១ | ឆ្មបមធ្យម | ៣៧០ ០០០ |
| ៤២ | ទន្តគិលានុបដ្ឋាកមធ្យម | ៣៧០ ០០០ |
| ៤៣ | អ្នកបច្ចេកទេសវិទ្យុសាស្ត្រ | ៣៧០ ០០០ |
| ៤៤ | គិលានុបដ្ឋាកមធ្យម | ៣៧០ ០០០ |
| ៤៥ | អ្នកបច្ចេកទេសថែទាំនិងអមវេជ្ជសាស្ត្របឋម | ៣៥០ ០០០ |
| ៤៦ | ឆ្មបបឋម | ៣៥០ ០០០ |
| ៤៧ | គិលានុបដ្ឋាកបឋម | ៣៥០ ០០០ |



www.pheakdeylaw.com